# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៦២

នាសប្តាហ៍នេះ ការពន្យារពេលសវនាការដាក់បង្ហាញឯកសារគន្លឹះ ដែលដើមឡើយគ្រោងនឹងចាប់ផ្តើមធ្វើនៅថ្ងៃចន្ទនេះ បាននាំឲ្យមានការផ្អាកកិច្ចដំណើរការនីតិវិធីសវនាការរហូតដល់ថ្ងៃព្រហស្បតិ៍។ ដោយបានប្រើប្រាស់រយៈពេលចំនួនពីរថ្ងៃនៃវគ្គសវនាការក្នុងសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូប ដែលត្រូវបានធ្វើឡើងក្នុងផ្នែកនៃសវនាការស្តាប់ព្យសនកម្មរបស់ជនរងគ្រោះ ពាក់ព័ន្ធនឹងផ្នែកជំនុំជម្រះលើកទីបួន ស្តីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង ហើយប្រការនេះ ជាការបន្ថែមលើការចាប់ផ្តើមសវនាការលើឯកសារ ដែលជាការដាក់បង្ហាញឯកសារគន្លឹះ ពាក់ព័ន្ធនឹងផ្នែកជំនុំជម្រះនេះក្នុងសំណុំរឿង០០២ វគ្គ២ ដោយការិយាល័យសហព្រះរាជអាជ្ញា និង ក្រុមសហមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី។[1] នៅថ្ងៃព្រហស្បតិ៍ លោក **ឆែ ហ៊ាប** បានផ្តល់សក្ខីកម្មជាលើកដំបូង ស្តីពីការបាត់បង់បង

[1] សវនាការលើឯកសារគន្លឹះ និងសវនាការស្តាប់ពីព្យសនកម្មរបស់ជនរងគ្រោះ ត្រូវបានរៀបចំឡើងនៅចុងបញ្ចប់នៃផ្នែកជំនុំជម្រះនីមួយៗ។ សវនាការលើឯកសារគន្លឹះ អនុញ្ញាតឲ្យភាគីទាំងអស់ធ្វើការដាក់បង្ហាញដល់ភាគីទៅវិញទៅមក នូវឯកសារគន្លឹះនានា ដែលមានភាពពាក់ព័ន្ធនឹងផ្នែកជំនុំជម្រះនីមួយៗ រីឯសវនាការស្តាប់ពីព្យសនកម្មរបស់ជនរងគ្រោះ អនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងមិនផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២ វគ្គ២ មានឱកាសរៀបរាប់ពីបទពិសោធន៍ស្តីពីការរងទុក្ខវេទនារបស់គាត់ដែលបានទទួលរងគ្រោះក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ សូមមើល ឯកសាររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី “ព័ត៌មានទី១ ស្តីពីសវនាការលើការដាក់បង្ហាញឯកសារគន្លឹះក្នុងសំណុំរឿង០០២ វគ្គ២ និងព័ត៌មានទី២ ស្តីពីសវនាការស្តាប់ពីព្យសនកម្មរងទុក្ខវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ វគ្គ២” (ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤) ឯកសារលេខ E315/1។ សម្រាប់សេចក្តីសង្ខេបស្តីពីសវនាការលើឯកសារគន្លឹះលើកទី១ ក្នុងសំណុំរឿង០០២ វគ្គ២ ស្តីពីសហករណ៍ស្រុកត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ សូមមើលរបាយការណ៍

ប្អូនបង្កើតចំនួនប្រាំនាក់ ក្នុងចំនោមបងប្អូនប្រុសស្រីទាំងប្រាំបីនាក់របស់គាត់ ក្នុងអំឡុងពេលនៃការបោសសម្អាតក្នុងកងពលលេខ៣១០ ហើយជាពិសេសនោះ គឺការស្លាប់បងប្រុសច្បងរបស់គាត់ឈ្មោះ **ឆៃ ហ៊ាយ** ដែលក្រុមគ្រួសារគាត់ត្រូវបានគេសម្លាប់ចោលទាំងអស់ផងដែរ។ បន្ទាប់មក គឺអ្នកស្រី **ភួង យ៉ាត** បានផ្តល់សក្ខីកម្មអំពីការបាត់បង់បងប្អូនស្រីរបស់គាត់ ដែលគាត់បានដឹងអំពីរឿងនេះនៅក្រោយរបបនេះ ថាបងប្អូនស្រីរបស់គាត់ត្រូវបានគេសម្លាប់នៅមន្ទីរស-២១។ ដើមបណ្តឹងរដ្ឋប្បវេណីចុងក្រោយ គឺ អ្នកស្រី **រស់ ជូស៊ីអ៊ី** បាន ផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោទ្យទ៍ពីទីក្រុងប៉ារីស អំពីការរងទុក្ខនានាដែលអ្នកស្រីបានឆ្លងកាត់កន្លងមក ដោយសារតែស្វាមីរបស់គាត់ឈ្មោះ **រស់ សារិន** ត្រូវបានគេសម្លាប់នៅមន្ទីស–២១។[2] នៅសប្តាហ៍បន្ទាប់ សវនាការស្តាប់ពីព្យសនកម្មរបស់ជនរងគ្រោះ នឹងត្រូវរៀបចំបញ្ចប់នៅថ្ងៃចន្ទ ជាមួយនឹងការស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋ

---

របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ២ លេខ១៧ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី១៤ (ចុះថ្ងៃទី២៧ ដល់៣០ ខែមេសា ឆ្នាំ២០១៥)។ សវនាការលើឯកសារគន្លឹះបន្ទាប់ ត្រូវបានរៀបចំនៅចុងបញ្ចប់នៃផ្នែកជំនុំជម្រះស្តីពីការរដ្ឋានការងារទាំងបី សូមមើលរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ២ លេខ២៨ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី២៥ (ចុះថ្ងៃទី២៤ ដល់ទី២៧ ខែសីហា ឆ្នាំ២០១៥) និងលេខ២៩ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី២៦ (ចុះថ្ងៃទី១ ដល់ទី៣ ខែកញ្ញា ឆ្នាំ២០១៥)។ សវនាការលើឯកសារគន្លឹះលើកទីបីនាពេលថ្មីៗនេះ បានផ្តោតលើការប្រព្រឹត្តទៅលើក្រុមគោលដៅ សូមមើលរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ២ លេខ៤៤ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៤១ (ចុះថ្ងៃទី២៣ ដល់ទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦) ទំព័រ ១ដល់៤។ សម្រាប់ព័ត៌មានស្តីពីសនាវការស្តាប់ព្យសនកម្មលើកទីមួយនៅចុងបញ្ចប់នៃផ្នែកជំនុំជម្រះលើកទីមួយ ស្តីពីសហករណ៍ស្រុកត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ សូមមើលរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ២ លេខ១៥ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី១២ (ចុះថ្ងៃទី៣០ ខែមីនា ដល់ទី៣ ខែមេសា ឆ្នាំ២០១៥) ទំព័រ១ដល់៧។ សម្រាប់សវនាការស្តាប់ព្យសនកម្មលើកទីពីរនៅចុងបញ្ចប់នៃផ្នែកជំនុំជម្រះ ស្តីពីការរដ្ឋានការងារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សូមមើលរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ២ លេខ២៩ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី២៦ (ចុះថ្ងៃទី១ ដល់ទី៣ ខែកញ្ញា ឆ្នាំ២០១៥) ទំព័រ១ដល់៤។ សម្រាប់សវនាការស្តាប់ព្យសនកម្មលើកទីបីនាពេលថ្មីៗនេះ ស្តីពីការប្រព្រឹត្តទៅលើក្រុមគោលដៅ សូមមើលរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ២ លេខ៤៥ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៤២ (ចុះថ្ងៃទី២៩ ខែកុម្ភៈ ដល់ទី៣ ខែមីនា ឆ្នាំ២០១៦) ទំព័រ១ដល់៧។

[2] ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកស្រី ***រស់ ជូស៊ីអ៊ី*** ត្រូវបានដកស្រង់ដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សី **កាំង ហ្គេចអ៊ាវ** ហៅ **ឌុច**។ មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី គឺលោកស្រី **ម៉ារ៉ា ហ្គីរូដ** (Marie Guiraud) បានចោទសួរទៅកាន់សាក្សី **ឌុច** អំពីស្វាមីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺលោក **រស់ សារិន** ដែលត្រូវបានឲ្យដឹងថាបានស្លាប់នៅមន្ទីរស-២១។ សាក្សី **ឌុច** បានអះអាងដោយមិនចងចាំឈ្មោះ **រស់ សារិន** នេះទេ។ សូមមើលរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ២ លេខ៥៦ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៥៣ (ចុះថ្ងៃទី៦ ដល់ទី៩ ខែមិថុនា ឆ្នាំ២០១៦) ទំព័រ៨។ អ្នកឃ្លាំមើលសវនាការ បានធ្វើការកត់សម្គាល់ថា ក្នុងរបាយការណ៍មុនៗ ឈ្មោះនេះត្រូវបានសរសេរប្រកបជាភាសាអង់គ្លេសថា Ruos Sarin ក៏ប៉ុន្តែយើងខ្ញុំសូមធ្វើការកែតម្រូវដោយប្រើប្រាស់ការសរសេរថា Ros Sarin វិញ ដើម្បីធ្វើឲ្យមានភាពស្របគ្នាទៅនឹងឯកសាររបស់ អ.វ.ត.ក។

ប្បវេណីចំនួនបីរូបបន្ថែមទៀត[3] ហើយបន្ទាប់មកនឹងរៀបចំការបិទបញ្ចប់សវនាការលើឯកសារគន្លឹះនៅថ្ងៃអង្គារ ជាមួយនឹងការឆ្លើយតបពីសំណាក់ក្រុមមេធាវីការពារក្តី។

[*] របាយការណ៍នេះ ត្រូវបានសរសេរដោយ ប្រ៊ីតនី អូលីណា ឆោ (Britni Olina Chau), ខេតលីន កាហ្វហ្រ៊ៀ (Caitlin McCaffrie), និន វុទ្ធី, តាយ លីណា, ធំ ស្ថាពរ, អាលីណា យូត្រាតា (Alina Utrata) និង ភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

[3] មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានគូសបញ្ជាក់ថា សាក្សីដែលសេសសល់ ដែលនឹងដាក់បញ្ចូលក្នុងសំណុំរឿង រួមមាន៖ សាក្សីដែលជាជនរងគ្រោះដោយប្រយោលក្នុងប្រធានបទមន្ទីរសន្តិសុខភ្នំក្រោល ម្នាក់ទៀតក៏ជាជនរងគ្រោះដោយប្រយោលក្នុងប្រធានបទមន្ទីរសន្តិសុខ ស-២១ ហើយសាក្សីចុងក្រោយជាជនរងគ្រោះដោយផ្ទាល់ក្នុងប្រធានបទនៃការបោសសម្អាតក្នុងភូមិភាគបូព៌ា សូមមើល ឯកសាររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី "ស្តីពីសារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អំពីបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងមកផ្តល់សក្ខីកម្មនាសនាវការលើផលប៉ះពាល់ និងព្យសនកម្មដែលបាតទទួលរង" (ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១៦) ឯកសារលេខ E315/1/6។